**សកម្មភាព** ៖ **ល្បែងការងារមួយណាដែលខ្ញុំធ្វើ?**

**ភាសាខ្មែរ**

ស្តាប់ (ស្តាប់គេនិយាយ និងមានសម្ថភាពស្តាប់ដោយធ្វើតាម)

បំណិនក្នុងសង្គម (ចំណេះដឹងអំពីសហគមន៍)

**គោលបំណង**

**(ភាសាខ្មែរ)** ប្រាប់បានខ្លះពីដំណើររឿង តាមរយៈការសរសេរពាក្យដាក់លើក្តាខៀនដែលបានបង្ហាញ ឬសួរសំណួរ។

ប្រាប់ពីសកម្មភាពតាមដំណាក់កាលដោយអនុវត្តតាមការណែនាំ។

ប្រាប់ពីឈ្មោះសម្ភារតាមមុខរបរ ឬការងារ។

ប្រាប់ពីឈ្មោះ និងមុខងារទីកន្លែងសំខាន់ៗ។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ គ្មាន

**ការរៀបចំ** ៖ គ្មាន

**សេចក្តីណែនាំ៖**

1. សួរសំណួរទៅក្មេងៗ រួចសរសេរពាក្យដែលជាចម្លើយក្មេងៗនៅលើក្តាខៀន ។
   តើអ្នកធ្វើការនៅសាលារៀនត្រូវបានគេហៅថាអ្វី?
   ចម្លើយ៖ គ្រូបង្រៀន
   តើគ្រូបង្រៀនប្រើឧបករណ៍អ្វីខ្លះនៅពេលបង្រៀន?
   ចម្លើយ៖ សម្ភារឧបទេស ប៊ិច សៀវភៅក្រុម បន្ទាត់ រូបភាព ដីស ប៊ិចហ្វឺត ក្រដាស ។
   តើគ្រូបង្រៀនធ្វើការនៅកន្លែងណា?
   ចម្លើយ៖ សាលារៀន
2. ផ្តល់ឧទាហរណ៍ ២ ឬ ៣ ដើម្បីឱ្យក្មេងៗទាយការងារដែលអ្នកកំពុងពិពណ៌នា។
   ឧទាហរណ៍៖ ខ្ញុំបានដេរអាវសិស្សសាលា។ តើនេះជាការងាអ្វី? (ចម្លើយ៖ជាងកាត់ដេរ)
3. សួរក្មេងៗថា៖តើកូនៗណាអាចពិពណ៌នាអំពីរការងារបានដែរឬទេ? ពិពណ៌នាដូចអ្នកគ្រូ។

ចំណុចសំខាន់នៃមេរៀនគឺ ឱ្យកុមាររៀបរាប់ពីការងារដោយមិនប្រាប់ថាវាជាអ្វី។
ឧទាហរណ៍. ខ្ញុំធ្វើនំប៉័ង និងនំបារាំង។ (ចម្លើយៈ អ្នកធ្វើនំប៉័ង)
ខ្ញុំប្រើដីស និងក្ដារខៀន។ (ចម្លើយៈ គ្រូបង្រៀន) - ល -

4. សម្រាប់ក្មេងៗណាដែលជ្រើសរើសការងារដូចគ្នា ត្រូវលើកចិត្តឱ្យក្មេងនោះពិពណ៌នាទៅតាមវិធីផ្សេងៗគ្នា។ឧទាហរណ៍. កុមារ ២នាក់ជ្រើសរើសការងារដូចគ្នាម្នាក់អាចពិពណ៌នាអំពីកន្លែងធ្វើការ ហើយម្នាក់ទៀតអាចពិពណ៌នាអំពីឧបករណ៍ដែលប្រើនៅកន្លែងធ្វើការក៏បានដែរ។